**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ០០៥ ស.អ.យ.

*រាជធានីភ្នំពេញ,ថ្ងៃទី០១ ខែមេសា ឆ្នាំ ២០១៦*

# សារាចរណែនាំ

## ស្តីពី

## ការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន

ដើម្បីអនុវត្តតាមអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ឱ្យបានទាន់ពេលវេលា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមធ្វើការណែនាំដូចខាងក្រោម ៖

១-ត្រូវបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ទៅតាម៦កម្រិត រួមមាន ៖

- កម្រិត១ : របបសន្តិសុខសង្គមសរុបប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី ៣០០ ០០០(បីសែន)រៀល ដល់ត្រឹម ៣៣០ ០០០(បីសែនបីម៉ឺន)រៀល ត្រូវបន្ថែមឱ្យដល់ត្រឹម ៣៦០ ០០០ (បីសែនប្រាំមួយម៉ឺន)រៀលក្នុង១(មួយ)ខែ
- កម្រិត២ : របបសន្តិសុខសង្គមសរុបប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី ៣៣០ ០០១(បីសែនបីម៉ឺនមួយ)រៀល ដល់ត្រឹម ៣៩៥ ០០០(បីសែនប្រាំបួនម៉ឺនប្រាំពាន់)រៀល ត្រូវផ្តល់ជូនបន្ថែមចំនួន ៣០ ០០០ (បីម៉ឺន)រៀលក្នុង១(មួយ)ខែ
- កម្រិត៣ : របបសន្តិសុខសង្គមសរុបប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី ៣៩៥ ០០១(បីសែនប្រាំបួនម៉ឺនប្រាំពាន់មួយ)រៀល ដល់ត្រឹម ៤០០ ០០០(បួនសែន)រៀល ត្រូវបន្ថែមឱ្យដល់ត្រឹម ៤២៥ ០០០ (បួនសែនពីរម៉ឺនប្រាំពាន់)រៀលក្នុង១(មួយ)ខែ
- កម្រិត៤ : របបសន្តិសុខសង្គមសរុបប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី ៤០០ ០០១(បួនសែនមួយ)រៀល ដល់ត្រឹម ៤៩៥ ០០០ (បួនសែនប្រាំបួនម៉ឺនប្រាំពាន់)រៀល ត្រូវផ្តល់ជូនបន្ថែមចំនួន ២៥ ០០០ (ពីរម៉ឺនប្រាំពាន់)រៀលក្នុង១(មួយ)ខែ
- កម្រិត៥ : របបសន្តិសុខសង្គមសរុបប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី ៤៩៥ ០០១(បួនសែនប្រាំបួនម៉ឺនប្រាំពាន់មួយ)រៀល ដល់ត្រឹម ៥០០ ០០០(ប្រាំសែន)រៀល ត្រូវបន្ថែមឱ្យដល់ត្រឹម ៥២០ ០០០(ប្រាំសែនពីរម៉ឺន)រៀលក្នុង១(មួយ)ខែ
- កម្រិត៦ : របបសន្តិសុខសង្គមសរុបប្រចាំខែបច្ចុប្បន្នចាប់ពី ៥០០ ០០១(ប្រាំសែនមួយ)រៀល ឡើងទៅ ត្រូវផ្តល់ជូនបន្ថែមចំនួន ២០ ០០០(ពីរម៉ឺន)រៀលក្នុង១(មួយ)ខែ។

២-សារាចរណែនាំនេះ មានវិសាលភាពអនុវត្តចំពោះ ៖

- និវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលជាអតីតមន្ត្រីរាជការស៊ីវិល
- និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការដែលជាអតីតយុទ្ធជន



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ. ទូរស័ព្ទ/ទូរសារៈ (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 72608

មន្ត្រីរាជការដែលទទួលបានការដំឡើងតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានអនុលោមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលត្រូវដាក់ឱ្យចូលនិវត្តន៍ចាប់ពីខែមករា ឆ្នាំ២០១៦ មិនត្រូវទទួលបានការបន្ថែមរបបសន្តិសុខសង្គម ដូចមានកំណត់ក្នុងចំណុច១នៃសារាចរណែនាំនេះឡើយ ។

៣-ការអនុវត្ត ៖

- អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ដែលបានទទួលការបន្ថែមរបបសន្តិសុខសង្គមប្រចាំខែក្នុងកម្រិតណាមួយខាងលើរួចហើយ មិនអាចទទួលបានកម្រិតផ្សេងទៀតឡើយ ។

- របបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនប្រចាំខែ ដែលបានកំណត់ក្នុងចំណុច១ខាងលើ នឹងត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ តទៅ ។

- ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត មានភារកិច្ចត្រូវរៀបចំបន្ថែមរបបសន្តិសុខសង្គមតាមកម្រិតជូនអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ឱ្យបានទាន់ពេលវេលា ។

គ្រប់ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងបេឡាជាតិអតីតយុទ្ធជន ត្រូវអនុវត្តតាមស្មារតី នៃខ្លឹមសារសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាព ។

រដ្ឋមន្ត្រី

វង សូត

**កន្លែងទទួល:**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សាភិបាលនៃប.ជ.ស.
- ក្រុមប្រឹក្សាភិបាលនៃប.ជ.អ.
- គ្រប់សាលារាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ